ផ្សព្វផ្សាយថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ១៩៩៨

# ទីស្តីការរដ្ឋមន្ត្រី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ប្រកាស

## ប្រកាសលេខ ៦១២ ប្រក.កសក
## ស្តីពី
## ការបង្កើតឯកសណ្ឋាន និង សញ្ញាសំគាល់ របស់អង្គការ ត្រួតពិនិត្យសុខភាពសត្វ និង អនាម័យ ផលិតផល មានដើមកំណើតពីសត្វ

រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

-បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩៨ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

-តាមសំណើរបស់ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល

**សំរេច**

**មាត្រា១ :** អនុញ្ញាតឲ្យអង្គការត្រួតពិនិត្យសុខភាពសត្វ និង អនាម័យផលិតផលមានដើមកំណើតពីសត្វ បង្កើតឯកសណ្ឋាន និង សញ្ញាសំគាល់ដូចមានកំណត់ក្នុងឯកសារឧបសម្ព័ន្ធភ្ជាប់ជាមួយសម្រាប់មន្ត្រីពិនិត្យសុខភាពសត្វ និង អនាម័យផលិតផលមានដើមកំណើតពីសត្វ ដើម្បីប្រើប្រាស់ក្នុងពេលប្រត្តិបត្តិការ និង ពិធីផ្សេង ៗ ។

**មាត្រា២ :-** ក្នុងពេលប្រត្តិបត្តិការ មន្ត្រីពិនិត្យសុខភាពសត្វ និង អនាម័យផលិតផលមានដើមកំណើតពីសត្វត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសំគាល់ និង ត្រូវមានលិខិតបញ្ជាបេសកកម្មព្រមទាំងលិខិតសំគាល់ខ្លួនជាប់ជាមួយ ។ ក្នុងពិធីផ្សេង ៗ បើចាំបាច់ត្រូវស្លៀកពាក់ឯកសណ្ឋាននិងសញ្ញាសំគាល់ដែរ ។

**មាត្រា ៣ :-** ជនក្លែងបន្លំ ដោយស្លៀកពាក់ឯកសណ្ឋាន និង សញ្ញាសំគាល់ដូចចែងក្នុងមាត្រា១ ដើម្បីបន្លំធ្វើជាមន្ត្រីត្រួតពិនិត្យសុខភាពសត្វ និង អនាម័យ ផលិតផលមានដើមកំណើតពីសត្វ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារពាក់ពន្ធ័ហើយផ្ទុយ នឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** ប្រធានមន្ទីរក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន គណនេយ្យហិរញ្ញវត្ថុ ប្រធាននាយក

ដ្ឋាន ផែនការ-ស្ថិតិ ប្រធាន គណៈកម្មាធិការ ត្រួតពិនិត្យ ប្រធាននាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល ប្រធានមន្ទីរ កសិកម្ម ខេត្ត ក្រុងប្រធាន ការិយាល័យ ផលិតកម្ម និង បសុព្យាបាលខេត្ត ក្រុងត្រូវទទួល បន្ទុករៀងៗខ្លួន អនុវត្តតាមប្រកាសនេះ ។

មាត្រា ៦ :-ប្រកាសនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ជ.រដ្ឋមន្ត្រីក្រសួងកសិកម្ម
អនុរដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ម៉ៅ សំអឿន

* * *

ភ្នំពេញ ថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ១៩៩៤

# ឯកសារឧបសម្ព័ន្ធ

## ស្តីពី

## ឯកសណ្ឋាន និង សញ្ញាសំគាល់
## របស់អង្គការ ត្រួតពិនិត្យសុខភាពសត្វ និង
## អនាម័យផលិតផលមានដើមកំណើតពីសត្វ

I ឯកសណ្ឋាន

-សម្រាប់ស្លៀកពាក់ក្នុងពេលប្រតិបត្តិការត្រួតពិនិត្យ សុខភាពសត្វ និង អនាម័យផលិតផល មានដើមកំណើតពីសត្វនិងក្នុងពិធីផ្សេងៗ ។ អាវធ្វើពីក្រណាត់សីម្លីពណ៌សនិងខោធ្វើពីក្រណាត់សីម្លីពណ៌ខៀវទឹកប៊ិច ។

រូបភាព និង ម្ជុក

-អាវដៃវែង ឬ ដៃខ្លីកឧបប៉ូលស្មា មានហោប៉ៅលើពីរ ដេរប៉ះដោយបត់ផ្នត់ចំកណ្តាលនិងមានគម្របរាងស្លឹកពោធិ កាត់ស្រុងវែងសម្រាប់ដាក់ក្នុងខោ ។

ខោជើងវែង ចង្កេះត ផ្នូវបង្កប់ជីបខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅពីរខាងក្រោយដេរបង្កប់មានគម្របរាងស្លឹកពោធិ និង ហោប៉ៅពីរទៀតនៅចំហៀង ដេរបង្កប់តាមថ្នេរ ។

-ស្បែកជើងពណ៌ខ្មៅ និង ស្រោមជើងពណ៌ខ្មៅ

-ខ្សែក្រវ៉ាត់ពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស

ចំពោះមន្ត្រីរាជការនារី ស្លៀកពាក់សំពត់ហ្សីបក្រោមជង្គង់ផែកក្រោយ ឬ ខោ និង អាវម៉ូតដូចខាងលើ តែមានជីបចង្កេះ ។

II . ផ្លាកសញ្ញាសំគាល់

ផ្លាកសញ្ញាសំគាល់របស់អង្គការត្រួតពិនិត្យសុខភាពសត្វ និង អនាម័យផលិតផល មានដើមកំណើតពីសត្វ កំណត់ដូចខាងក្រោមសម្រាប់ពាក់លើម្ជុកកាស្កេត ចុងកអាវឆ្វេងស្តាំ និង ហោប៉ៅអាវស្តាំ ។

ក. រូបព្រះសង្ខ្លា :

រូបព្រះសង្ខ្លាយកតាមសម័យសង្គមរាស្ត្រនិយមធ្វើពីលោហធាតុពណ៌មាស សម្រាប់ពាក់លើមួកកាស្កែតដែលមាន ទំហំកំពស់ ៧,៨ ស.ម ទទឹង ៦,៨ ស.ម ។

ខ . ផ្លាកសញ្ញាសម្រាប់ពាក់លើចុងកអាវឆ្វេងស្តាំ

ផ្ទាំងនៃសញ្ញាសំគាល់មានផ្ទៃពណ៌មាស រាងជារង្វង់មូលមានវិជ្ជមាត្រ ៣,៥ ស.ម ។

-នៅចំកណ្តាលមានសញ្ញាកាកបាទ ពណ៌ខៀវទឹកប៊ិចទំហំ១,៧ស.ម គុណ នឹង ១,៧ ស.ម ជ្រុងនិមួយៗ មានប្រវែង០,៥ ស.ម ។

-នៅខាងក្រោមសញ្ញាកាកបាទមានសរសេរអក្សរថា«បសុពេទ្យ» ពណ៌មាសស្របតាមរង្វង់មូលនៃផ្លាកសញ្ញា ទំហំអក្សរ ០,៨ស.ម ។

-នៅជាយជុំវិញមានក្បាច់ជាកម្រងខ្សែសយពណ៌មាស មានកំពស់ ទទឹង ០,៣ស.ម ។

III . អំពីមួក

មួកកាស្កែតធ្វើពីក្រណាត់សឺមីពណ៌ស ដែលផ្នែកខាងមុខលើកណ្តាប់វ័ណ្ឌមានភ្ជាប់រូបព្រះសង្ខ្លាពណ៌មាស ទំហំកំពស់ ៧,៨ស.ម ទទឹង ៦,៨ស.ម ។ ប៉ែកខាងក្រោមនៃជើងមួក និង ក្រោមព្រះសង្ខ្លាមានកណ្តាប់វ័ណ្ឌធ្វើពីក្រណាត់ខ្សែនពណ៌ទឹកប៊ិច ព័ទ្ធជុំវិញ ។ ខាងក្រោមកណ្តាប់វ័ណ្ឌប៉ែក ខាងមុខមានក្បាំងមុខពណ៌ខ្មៅ ។

មួកកាស្កែតត្រូវបានកំណត់បែងចែកជាបួនប្រភេទ :

-ផ្នែកខាងមុខក្រោមកណ្តាប់វ័ណ្ឌដែលនៅលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅចុងខ្សែទាំងពីរភ្ជាប់ដោយខ្សៀវរូបព្រះសង្ខ្លា ពណ៌មាស ។ នៅលើក្បាំងមួកមានប៉ានក្បាច់ភ្ញីទេសខិន ពណ៌មាស ទម្រង់ស្នែងក្របីដល់ជើងមួកសម្រាប់សំគាល់មន្ត្រីចាប់ពី ថ្នាក់នាយកដ្ឋានឡើងទៅ ។

-ផ្តែកខាងមុខក្រោមកណ្តាប់វ័ណ្ឌដែលនៅលើក្បាំងមានកម្រងខ្សែសយ ពណ៌មាសព្រមទាំងនៅចុងខ្សែទាំងពីរមានភ្ជាប់ដោយខ្សែវរូបព្រះសង្ហា ពណ៌មាស ។ នៅលើក្បាំងម្ជុកមានប៉ានក្បាច់ភ្ជីពណ៌ មាសទម្រង់ស្លែង ក្របី ដោយចុងសងខាងទុកចន្លោះ ៨ស.ម ពីជើងម្ជុកសម្រាប់សំគាល់ មន្ត្រី ថ្នាក់ការិយាល័យ ។

-ផ្តែកខាងមុខក្រោមកណ្តាប់វ័ណ្ឌដែលនៅលើក្បាំង មានកម្រងខ្សែសយពណ៌មាស ព្រមទាំងនៅមុខខ្សែទាំងពីរ មានភ្ជាប់ ដោយខ្សែវរូវព្រះសង្ហាពណ៌មាស។នៅលើក្បាំងម្ជុកមានវ័ណ្ឌទំហំ ០,៥ស.ម ពណ៌មាសព័ទ្ធវង់ដល់ជើងម្ជុក សម្រាប់សំគាល់មន្ត្រីជាប្រធាន ស្នាក់ការត្រួតពិនិត្យសុខភាពសត្វ និង អនាម័យផលិតផលមាន ដើមកំ ណើតពីសត្វ ។

-ផ្តែកខាងមុខក្រោមកណ្តាប់វ័ណ្ឌ ដែលនៅលើក្បាំងមានកម្រងខ្សែសយ ពណ៌មាសព្រមទាំងនៅចុងខ្សែទាំងពីរមានភ្ជាប់ដោយខ្សែវរូបព្រះសង្ហា ពណ៌មាសសំរាប់សំគាល់ មន្ត្រីជាភ្នាក់ងារ ត្រួតពិនិត្យសុខភាពសត្វ និង អនាម័យ ផលិតផលដែលមានដើមកំណើតពីសត្វ ។

IV . ផ្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅអាវស្តាំ

ផ្លាកឈ្មោះធ្វើពីជ័រភ្លឺថ្លារឹងកម្រាស់ ០,១ស.ម បណ្តោយ០,៨ស.ម មាន ពណ៌ផ្ទៃមេឃខ្ចីនៅចំកណ្តាលផ្លាកមានសរសេរឈ្មោះមន្ត្រីត្រួតពិនិត្យសុខ ភាពសត្វ និង អនាម័យផលិតផលមានដើមកំណើតពីសត្វ ។ អក្សរ ពណ៌ស មានទំហំ១ ស.ម ។

ជ.រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
អនុរដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
ម៉ៅ សំរឿន

* * *